# តម្រាសង់ផ្ទះ

## ខែសង់ផ្ទះ

សង់ផ្ទះក្នុងខែ១ នឹងមានសេរីសួស្តី លាភសក្ការៈហូរចូលនិងបានសេចក្តីសុខសាន ត្រជាក់ត្រជុំ។

សង់ផ្ទះក្នុងខែ២ ល្អប្រសើរ និងបានសុខ សត្រូវប៉ុនប៉ងប្រទូស្តរាយមិនបាន បរិបូរណ៍ដោយញាតិ មិត្តសន្តាន ។

សង់ផ្ទះក្នុងខែ៣ នឹងមានទុក្ខទោសភ័យដល់ខ្លួន មិនល្អឡើយ ។

សង់ផ្ទះក្នុងខែ៤ នឹងបានសេចក្តីសុខសាន្ត លាភសក្ការៈហូរចូលជារឿយៗ ។

សង់ផ្ទះក្នុងខែ៥ មិនល្អឡើយ និងមានកើតសេចក្តីក្តៅក្រហាយក្នុងចិត្ត ។

សង់ផ្ទះក្នុងខែ៦ ល្អប្រសើរ និងត្រូវបានលាភសក្ការៈគួរជាទីពេញចិត្ត ។

សង់ផ្ទះក្នុងខែ៧ មិនល្អឡើយ និងត្រូវមានខូចខាតលាភសក្ការៈផ្ទាល់ខ្លួន ។

សង់ផ្ទះក្នុងខែ៨ អាក្រក់ណាស់ និងមានកើតក្តីក្តៅក្រហាយក្នុងចិត្ត ទ្រព្យសម្បត្តិបានមកថែ រក្សាមិនគង់ ។

សង់ផ្ទះក្នុងខែ៩ ល្អណាស់ និងមានលាភសក្ការៈគេនាំមកឱ្យ ។

សង់ផ្ទះក្នុងខែ១០ មិនល្អ និងត្រូវមានជំងឺមកបៀតបៀនជារឿយៗ ។

សង់ផ្ទះក្នុងខែ១១ អាក្រក់ណាស់ គួរជៀសវាង ព្រោះនឹងមានគ្រោះអន្តរាយធ្លាក់ដល់ខ្លួន ។

សង់ផ្ទះក្នុងខែ១១ ល្អប្រសើរ និងត្រូវបានបុណ្យសក្តិ មាសប្រាក់បរិបូរណ៍ គួរជាទីពេញចិត្ត ។ ថ្ងៃសង់ផ្ទះ

សង់ផ្ទះក្នុងថ្ងៃអាទិត្យ មិនល្អឡើយ ច្រើនលេចឮពាក្យសំដីរកាំរកូសក្នុងផ្ទៃគ្រួសារ ។

សង់ផ្ទះក្នុងថ្ងៃច័ន្ទ ល្អប្រសើរណាស់ ព្រោះជាថ្ងៃដើមទ្រព្យ និងមានគេយកលាភយមកឱ្យ ។

សង់ផ្ទះក្នុងថ្ងៃអង្គារ៍ មិនល្អ ព្រោះជាថ្ងៃរឹងរូស និងមានទុក្ខទោសភ័យដល់ខ្លួន ។

សង់ផ្ទះក្នុងថ្ងៃពុធ ល្អណាស់ និងបានលាភគួរជាទីពេញចិត្ត ។

សង់ផ្ទះក្នុងថ្ងៃព្រហស្បតិ៍ ល្អណាស់ និងបានសុខសាន្ត ត្រជាក់ត្រជុំ សម្បូរសប្បាយ ។

សង់ផ្ទះក្នុងថ្ងៃសុក្រ នឹងបានល្អប្រសើរ និងបានលាភសក្ការៈគួរជាទីពេញចិត្ត ។

សង់ផ្ទះក្នុងថ្ងៃសៅរ៍ អាក្រក់ណាស់ និងមានសេចក្តីទុក្ខក្តៅក្រហាយដល់ខ្លួនជារឿយៗ ។

ពិធីជ្រើសរើសរកពេលល្អ
បើធ្វើកិច្ចការសព្វសារពើ ឬ រៀបអាពាហ៍ពិពាហ៍ ប្រាថ្នាឱ្យមានសេរីសួស្តី ជោគជ័យមង្គល ឱ្យមើលត្រង់ទេតវាឱ្យឫក្សដំនេះ :
ខាងខ្នើត
ថ្ងៃ១កើត ទេវាចរនៅចំបេះដូង ទេវតាឱ្យឫក្សល្អអស្ចារ្យ បើនឹងធ្វើកិច្ចការ ឬរៀបអាពាហ៍ ពិពាហ៍ មង្គលការ នឹងបានល្អប្រសើរ ជោគល្អមានចាប់ពីម៉ោង៦ព្រឹកដល់ម៉ោង៦ល្ងាច ជោគអាក្រក់មានចាប់ពីម៉ោង៦ល្ងាច ដល់ម៉ោង៩ភ្លឺ ។
ថ្ងៃ២កើត ទេវាចរស្ថិតនៅត្រង់ជើង ទេវតាហាមឫក្ស មិនឱ្យរៀបអាពាហ៍ពិពាហ៍ ឬសង់ផ្ទះ និងស្តីដណ្តឹងកូន ទំនាយថា នឹងមានខាតបង់លាភសក្ការៈ ឬព្រាត់ប្រាសប្តីប្រពន្ធ ឬថានឹងកើតរឿងហេតុនាំឱ្យអាស្រូវ គួរកុំពាក់សំលៀកបំពាក់ថ្មី ជោគអាក្រក់ចាប់ពីព្រលឹមម៉ោង៦ព្រឹក ទៅដល់ពេលល្ងាច ជោគល្អចាប់ពីម៉ោង៦ល្ងាចទៅទល់នឹងមាន់រងាវភ្លឺ ។
ថ្ងៃ៣កើត ទេវាចរនៅត្រង់ចង្ការ ទេវតាមហាឫក្ស ការសង់ផ្ទះ ការដណ្តឹងកូនមិនល្អ ហាមកាប់ ព្រៃឈើ ឬរុះរើផ្ទះសម្បែងនឹងនាំឱ្យមានខាតបង់ទ្រព្យរបស់ ។ ជោគអាក្រក់មានចាប់ពីព្រលឹមព្រឹកម៉ោង ៦ ទៅទល់នឹងម៉ោងល្ងាច ឯជោគល្អចាប់ផ្តើមពីម៉ោង៦ល្ងាច ទៅទល់នឹងមាន់រងាវភ្លឺ ។
ថ្ងៃ៤កើត ទេវាចរស្ថិតនៅទីវាល ទេវតាឱ្យឫក្ស បើនឹងសង់ផ្ទះ ឬរៀបមង្គលការ ស្តីដណ្តឹងកូន ល្អណាស់ និងមានគេនាំលាភមកឱ្យ តែប្រយ័ត្នកុំចេញដើរឆ្ងាយ ក្រែងខូចបង់ទ្រព្យសម្បត្តិ កុំនិយាយរឿងណាដែលមិនល្អ ជោគល្អមានចាប់ពីព្រលឹមម៉ោង៦ ទៅទល់នឹងម៉ោង២រសៀល ជោគអាក្រក់ចាប់ពីម៉ោង២ថ្ងៃ រហូតទល់នឹងមាន់រងាវភ្លឺ ។
ថ្ងៃ៥កើត ទេវាចរស្ថិតនៅត្រង់អាកាស ទេវតាហាមឫក គួរកុំធ្វើពិធីមង្គលការ ឬសង់ផ្ទះជា ដើម នាំឱ្យព្រាត់ប្រាសគ្នា ឬខាតលាភសក្ការៈផ្សេងៗ បើធ្វើដំណើរឆ្ងាយតាមផ្លូវគោកនឹងបានជួបលាភ សក្ការៈ ហាមធ្វើដំណើរតាមផ្លូវទឹក បើនឹងកាត់សម្លៀកបំពាក់ថ្មី ឬជួញដូរនឹងបានល្អប្រសើរ ជោគអាក្រក់ចាប់ពីពេលព្រឹករហូតទល់នឹងថ្ងៃត្រង់ ជោគល្អចាប់ពីថ្ងៃត្រង់ ទៅទល់នឹងពាក់កណ្តាលអធ្រាត្រ ។
ថ្ងៃ៦កើត ទេវាចរស្ថិតនៅកណ្តាលថ្ងាស ទេតវាឱ្យឫក្ស បើនឹងធ្វើកិច្ចការ សង់ផ្ទះ ឬរៀបមង្គល ការល្អណាស់ បើលក់ដូរនឹងបានជោគលាភល្អ បើស្តីដណ្តឹងកូននឹងបានល្អប្រសើរ អាចថែរក្សាគ្នាបានយឺន យូរ

បើសេពគប់នឹងនាហ្មឺនមន្ត្រីនឹងបានកើតផលប្រយោជន៏ដូចចិត្តប្រាថ្នា ជោគល្អមានចាប់ពីពេលព្រឹក ជោគអាក្រក់ចាប់មានពីពេលថ្ងៃត្រង់ ទៅទល់ពាក់កណ្តាលអធ្រាត្រ ។

ថ្ងៃ៧កើត ទេវាចរស្ថិតនៅនឹងត្រចៀក ទេវាហាមឬក្ស កុំរៀបមង្គលការ កុំសង់ផ្ទះនាំឱ្យមាន ភ័យន្តរាយដល់ខ្លួន ឬព្រាត់ប្រាសគ្នា កុំកាត់សម្លៀកបំពាក់ថ្មី ឬជួញដូរគោក្របី ជោគកាចមានចាប់ពេល ព្រឹកទៅទល់នឹងថ្ងៃត្រង់ ជោគល្អមានចាប់ពីថ្ងៃត្រង់ ទៅទល់នឹងមាន់រងាវភ្លឺ ។

ថ្ងៃ៨កើត ទេវាចរស្ថិតនៅទាំង៤ខាងមុខក្រោយ ទេវតាហាមឬក្ស គួរកុំរៀបមង្គលការ ឬស្តី ដណ្តឹងកូន នឹងនាំឱ្យមានទុក្ខដល់ខ្លួន ឬត្រូវព្រាត់វិនាសគ្នា ជោគល្អមានចាប់ពីម៉ោង៦ព្រឹក ទល់នឹងម៉ោង ១២ថ្ងៃត្រង់ ជោគអាក្រក់មានចាប់ពីថ្ងៃត្រង់ទៅទល់នឹងមាន់រងាវភ្លឺ ។

ថ្ងៃ៩កើត ទេវាចរស្ថិតនៅក្នុងភ្នែក ទេវាឱ្យឬក្ស បើសង់ផ្ទះ ឬរៀបមង្គលការនឹងបានល្អប្រសើរ តែកុំធ្វើដំណើរទៅកាន់ទីឆ្ងាយ បើជួញដូរនឹងបានជួបលាភសក្ការៈគួរជាទីពេញចិត្ត ជោគល្អមានចាប់ពី ពេលថ្ងៃត្រង់ទៅទល់នឹងពាក់កណ្តាលអធ្រាត្រ ។

ថ្ងៃ១០កើត ទេវាចរស្ថិតនៅត្រង់ក្បាល ទេវតាហាមឬក្ស មិនឱ្យរៀបមង្គលការ ឬសង់ផ្ទះថ្មី មិនល្អ នាំឱ្យព្រាត់ប្រាសគ្នា ឬខាតបង់លាភសក្ការៈផ្សេងៗ កុំឱ្យស្តីដណ្តឹងកូន កុំកាត់សំលៀកបំពាក់ថ្មី ជោគកាចមានចាប់ពីពេលព្រឹកទល់នឹងថ្ងៃត្រង់ ជោគល្អមានចាប់ពីថ្ងៃត្រង់ទៅទល់ភ្លឺ ។

ថ្ងៃ១១កើត ទេវាចរស្ថិតនៅត្រង់ពោះ ទេវតាឱ្យឬក្ស បើនឹងសង់ផ្ទះ រៀបមង្គលការ ឬស្តី ដណ្តឹងកូន ល្អណាស់ និងបានលាភយសពីអ្នកធំ ជោគល្អមានចាប់ពីពេលព្រឹក ទៅទល់នឹងថ្ងៃរសៀល ជោគកាចចាប់មានពីរសៀលរហូតទល់ភ្លឺ ។

ថ្ងៃ១២កើត ទេវាចរស្ថិតនៅត្រង់ក្បាល ទេវតាហាមឬក្ស កុំសង់ផ្ទះថ្មី ឬរៀបមង្គលការ ឬស្តី ដណ្តឹងកូន ជាប្រការមិនល្អ កុំធ្វើដំណើរឆ្ងាយ ជោគកាចមានពីពេលព្រឹកទល់នឹងថ្ងៃរសៀល ជោគល្អចាប់ មានពីពេលរសៀលទៅទល់ភ្លឺ ។

ថ្ងៃ១៣កើត ទេវាចរស្ថិតនៅទីលាន ទេវតាឱ្យឬក្ស ក្នុងការសាង់សងផ្ទះ ឬរៀបមង្គលការ ស្តី ដណ្តឹងកូនបានល្អប្រសើរណាស់ នៅរួមរស់ជាមួយគ្នាបានសុខសាន្ត កុំយាត្រាផ្លូវឆ្ងាយ ជោគល្អមានពីពេល ព្រឹកទល់នឹងពេលរសៀល ជោគអាក្រក់មានចាប់ពីពេលរសៀល ទៅទល់នឹងពេលមាន់រងាវភ្លឺ ។

ថ្ងៃ១៤កើត ទេវាចរស្ថិតនៅត្រង់ស្មា ទេវតាហាមឫក្ស ការសង់ផ្ទះ ឬរៀបមង្គលការ ស្តីដណ្តឹង កូនហាមដាច់ខាត កុំទៅមកស្និទ្ធស្នាលនឹងនាហ្មឺន នាំឱ្យមានទុក្ខទោសដល់ខ្លួន ជោគកាចមានចាប់តាំងពីពេលព្រឹកទៅទល់នឹងថ្ងៃត្រង់ ជោគល្អមានចាប់ពីពេលថ្ងៃត្រង់ទៅទល់មាន់រងាវភ្លឺ ។
ថ្ងៃ១៥កើត ទេវាចរស្ថិតនៅកណ្តាលខ្នង ទេវតាឱ្យឫក្ស បើសង់ផ្ទះថ្មី ឬរៀបមង្គលការ ស្តី ដណ្តឹងកូនបានល្អប្រសើរណាស់ និងបានទ្រព្យសម្បត្តិ លាភកិត្តិយស ។ ជោគល្អមានចាប់ពីព្រលឹមទៅទល់នឹងថ្ងៃត្រង់ ជោគកាចមានចាប់ពីពេលថ្ងៃត្រង់ទៅទល់នឹងមាន់រងាវភ្លឺ ។

ខាងរនោច

ថ្ងៃ១រោច ទេវាចរស្ថិតនៅត្រង់ជើង ទេវតាឱ្យឫក្ស បើនឹងធ្វើការ សង់ផ្ទះថ្មី រៀបមង្គលការ ស្តីដណ្តឹងកូននឹងបានល្អប្រសើរ និងបានលាភយសពីនាហ្មឺនមន្ត្រី ជោគល្អមានចាប់ពីពេលព្រលឹមទល់នឹង ពេលរសៀលជោគអាក្រក់មានចាប់ពីពេលរសៀលទៅទល់ភ្លឺ ។
ថ្ងៃ២រោច ទេវាចរស្ថិតនៅត្រង់ដៃ ទេវតាហាមឫក្សក្នុងការសង់ផ្ទះថ្មី រៀបមង្គលការ ស្តីដណ្តឹងកូនហាមមិនល្អ កុំយាត្រាទៅឆ្ងាយ ឬកាត់សំលៀកបំពាក់ថ្មី ជោគកាចមានចាប់ពីពេលព្រឹកទៅទល់នឹងថ្ងៃត្រង់ ជោគល្អមានចាប់ពីថ្ងៃត្រង់រហូតដល់ភ្លឺ ។
ថ្ងៃ៣រោច ទេវាចរស្ថិតនៅត្រង់ជើង ទេវតាហាមឫក្ស កុំសង់ផ្ទះ ឬរៀបមង្គលការ ស្តីដណ្តឹង កូននឹងនាំឱ្យមានខាតបង់លាភសក្ការៈ ឬព្រាត់ប្រាសគ្នា កុំចូលព្រៃជ្រៅ កុំចងមិត្តនឹងនាហ្មឺនមន្ត្រី ជោគកាច់មានចាប់ពីពេលព្រឹកទៅដល់នឹងថ្ងៃត្រង់ ជោគល្អមានពីថ្ងៃត្រង់ទៅទល់នឹងមាន់រងាវ ។
ថ្ងៃ៤រោច ទេវាចរស្ថិតនៅត្រង់ធ្មេញ ទេវតាឱ្យឫក្ស ល្អត្រកាល បើនឹងសង់ផ្ទះ ឬរៀបមង្គល ការស្តីដណ្តឹងកូន ល្អប្រសើរ ជោគល្អមានចាប់ពីពេលព្រឹកទៅទល់នឹងថ្ងៃត្រង់ ជោគកាចមានចាប់ពីពេលថ្ងៃត្រង់ទៅទល់នឹងមាន់រងាវភ្លឺ ។
ថ្ងៃ៥រោច ទេវាចរស្ថិតនៅត្រង់ចង្ការ ទេវតាហាមឫក្ស កុំធ្វើមង្គលការ ឬសង់ផ្ទះថ្មី នឹងមានកើតរឿងហេតុ កុំសេពគប់នាហ្មឺនមន្ត្រី ជោគកាចមានពីពេលព្រលឹមទៅទល់នឹងរសៀល ជោគល្អមានពីរសៀលទល់មាន់រងាវភ្លឺ ។

ថ្ងៃ៦រោច ទេវាចរស្ថិតនៅត្រង់ថ្ពាស ទេវតាឱ្យឫក្ស បើសង់ផ្ទះថ្មី ឬសង់មង្គលការ ស្តីដណ្តឹងកូន បានល្អប្រសើរ ជោគល្អមានចាប់ពីពេលព្រឹក ទៅទល់នឹងថ្ងៃត្រង់ ជោគកាចមានចាប់ពីពេលថ្ងៃត្រង់ទៅទល់ភ្លឺ ។

ថ្ងៃ៧រោច ទេវាចរស្ថិតនៅត្រង់ខ្នង ទេវតាហាមឫក្ស កុំរៀបមង្គលការ ឬសង់ផ្ទះថ្មី បើធ្វើដំណើរឆ្ងាយនឹងមានលាភ ជោគល្អមានចាប់ពីពេលព្រឹកទៅទល់នឹងថ្ងៃត្រង់ ជោគកាចមានចាប់ពីពេលថ្ងៃត្រង់ទៅទល់ភ្លឺ ។

ថ្ងៃ៨រោច ទេវាចរស្ថិតនៅត្រង់មុខ ទេវតាហាមឫក្ស ក្នុងការសាងសង់ផ្ទះថ្មី ឬរៀបអាពាហ៍ពិពាហ៍សមិនល្អ កុំធ្វើដំណើរឆ្ងាយ ឬកាត់សំលៀកបំពាក់ថ្មី ជោគកាចមានចាប់ពីពេលព្រលឹម ដល់ថ្ងៃត្រង់ ជោគល្អមានចាប់ពីថ្ងៃត្រង់រហូតមាន់រងាវភ្លឺ ។

ថ្ងៃ៩រោច ទេវាចរស្ថិតនៅត្រង់ក្បាល ទេវតាឱ្យឫក្ស ធ្វើការ ឬសង់ផ្ទះថ្មី រៀបការកូនប្រុស-ស្រីនឹងបានល្អប្រសើរ កុំធ្វើដំណើរចរយាត្រាទៅឆ្ងាយ ជោគល្អមានចាប់ពីពេលព្រឹកទៅទល់ថ្ងៃត្រង់ ជោគកាចមានចាប់ពីពេលថ្ងៃត្រង់ទៅទល់ភ្លឺ ។

ថ្ងៃ១០រោច ទេវាចរស្ថិតនៅត្រង់៤ខាង ទេវតាហាមឫក្ស ការសង់ផ្ទះ ឬរៀបមង្គលការ ស្តីដណ្តឹងកូនមិនល្អ ជោគកាចចាប់ពីពេលព្រឹកទល់នឹងថ្ងៃត្រង់ ជោគល្អចាប់ពីថ្ងៃត្រង់ទៅទល់នឹងមាន់រងាវភ្លឺ ។

ថ្ងៃ១១រោច ទេវាចរស្ថិតនៅត្រង់ជើង ទេវតាឱ្យឫក្សល្អត្រកាល បើសង់ផ្ទះថ្មី ឬរៀបមង្គលការ ស្តីដណ្តឹងកូនបានល្អប្រសើរ ជោគល្អចាប់មានពីពេលព្រឹកដល់ថ្ងៃត្រង់ ជោគអាក្រក់ចាប់មានពីពេលថ្ងៃត្រង់រហូតមាន់រងាវភ្លឺ ។

ថ្ងៃ១២រោច ទេវាចរស្ថិតនៅត្រង់បាតជើង ទេវតាហាមឫក្ស បើសង់ផ្ទះថ្មី ឬរៀបមង្គលការ ស្តីដណ្តឹងកូនមិនល្អ  នឹងមានអន្តរាយដល់ខ្លួន ជោគកាចមានចាប់ពីពេលព្រឹកទៅទល់ថ្ងៃត្រង់ ជោគល្អចាប់ពីថ្ងៃត្រង់រហូតដល់ភ្លឺ ។

ថ្ងៃ១៣រោច ទេវាចរស្ថិតនៅត្រង់ត្រចៀក ទេវតាឱ្យឫក្ស បើសង់ផ្ទះថ្មី ឬសង់មង្គលការ ស្តីដណ្តឹងកូនបានល្អប្រសើរ  ជោគល្អមានចាប់ពីពេលព្រឹករហូតដល់ថ្ងៃត្រង់ ជោគកាចមានចាប់ពីថ្ងៃត្រង់រហូតដល់ភ្លឺ ។

ថ្ងៃ១៤រោច ទេវាចរស្ថិតនៅត្រង់មុខ ទេវតាឱ្យឫក្ស បើសង់ផ្ទះថ្មី ឬរៀបមង្គលការ ស្តីដណ្តឹងកូនបានល្អប្រសើរណាស់ ជោគល្អមានចាប់ពីពេលព្រឹកទៅទល់ថ្ងៃត្រង់ ជោគកាចមានចាប់ពីថ្ងៃត្រង់រហូតដល់មាន់រងាវភ្លឺ ។

ថ្ងៃ១៥រោច ទេវាចរស្ថិតនៅត្រង់បេះដូង ទេវតាឱ្យឫក្ស បើនឹងសង់ផ្ទះថ្មី ឬរៀបមង្គលការកូន ប្រុស ស្រី ស្តីដណ្តឹងកូនបានល្អប្រសើរណាស់ ជោគល្អមានពីពេលព្រលឹម ទៅទល់នឹងពេលល្ងាចយ៉ាង៣ ។